**AUSTRALIAN EMBASSY**
**PHNOM PENH**

## សេចក្ដីប្រកាសព័ត៌មាន

## ពលរដ្ឋអូស្ត្រាលីប្រមូលថវិកាចំនួន 75,000 ដុល្លា ដើម្បីឧបត្ថម្ភដល់ជនរងគ្រោះកម្ពុជាអំពីការជួញដូរមនុស្ស

នាថ្ងៃនេះ លោកជំទាវឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា **ម៉ាហ្គារ៉េត អាដាមសុន** (Margaret Adamson) បានធ្វើការស្វាគមន៍ដល់ការមកដល់រាជធានីភ្នំពេញ នូវក្រុមអ្នកជិះកង់ចំនួន21នាក់ មកពីប្រទេសអូស្ត្រាលី កាណាដា និងសហរដ្ឋអាមេរិក។ ក្រុមអ្នកជិះកង់ទាំងនេះនឹងជិះកង់នៅប្រទេសកម្ពុជា ដើម្បីប្រមូលថវិកាសំរាប់លើកកំពស់ការយល់ដឹងជាសាធារណៈ អំពីការជួញដូរមនុស្ស និងការរំលោភផ្លូវភេទលើស្ត្រី និងកុមារ។

ការជិះកង់ដែលមានរយៈចំងាយ 489គម ដែលធ្វើឡើងដើម្បីប្រយោជន៍សប្បុរសធម៌នេះ ត្រូវបានរៀបចំឡើងដោយអង្គការសំលឹងមើលឆ្ពោះទៅអនាគត ក្រោមផ្នែកមួយនៃគំរោងអនាគតឆ្នាំ2009។ ស្ថាបនិកនៃអង្គការសំលឹងមើលឆ្ពោះទៅអនាគត គឺលោកស្រី Stephanie Lorenzo ដែលជាស្ត្រីសញ្ជាតិអូស្ត្រាលីដ៏វ័យក្មេងមួយរូបក៏គ្រោងនឹងចូលរួមក្នុងការជិះកង់នេះដែរ។

លោកជំទាវឯកអគ្គរាជទូត និងលោកស្រី Lorenzo បានប្រគល់នូវមូលប្បទានប័ត្រដែលមានទឹកប្រាក់ចំនួន 75,000 ដុល្លាអាមេរិក ជូនលោកស្រីសូម៉ាលី ម៉ម ដែលជាប្រធានអង្គការអាហ្វេស៊ីបកម្ពុជា និងជាស្ថាបនិកមូលនិធិសូម៉ាលី ម៉ម។ ទឹកប្រាក់ទាំងនេះ ត្រូវបានឧបត្ថម្ភដោយសប្បុរសជនជាច្រើនតាមរយៈអ្នកជិះកង់។

លោកជំទាវឯកអគ្គរាជទូតបានមានប្រសាសន៍ថា "ក្រុមមនុស្សវ័យក្មេងទាំងនេះមានកំលាំងចិត្តខ្លាំងក្លាក្នុងការចូលរួមជាបុគ្គល ដើម្បីដោះស្រាយបញ្ហាដែលធ្ងន់ធ្ងរនៅលើពិភពលោក ជាពិសេសគឺកំលាំងចិត្តក្រោយពេលពួកគេបានអាននូវកិច្ចខំប្រឹងប្រែងដ៏អស្ចារ្យរបស់លោកស្រីសូម៉ាលី ម៉ម ដែលជាស្ថាបនិកនៃអង្គការអាហ្វេស៊ីប។ ខ្ញុំមានមោទនភាពយ៉ាងក្រៃលែងចំពោះកិច្ចប្រឹងប្រែងរបស់ពួកគេ ក្នុងការប្រមូលថវិការសំរាប់ជាប្រយោជន៍ដល់កិច្ចការមួយនេះ។"

ការជួញដូរស្ត្រីនិងកុមារដើម្បីបំរើផ្លូវភេទ ឬដើម្បីការកេងប្រវ័ញ្ចកំលាំងពលកម្ម គឺជាបញ្ហាដ៏ធ្ងន់ធ្ងរដែលកំពុងជួបប្រទះនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន រួមទាំងប្រទេសកម្ពុជាផងដែរ។ អូស្ត្រាលីបានឧបត្ថម្ភដល់គំរោងមួយចំនួននៅអនុតំបន់មហាទន្លេមេគង្គ ដើម្បីកាត់បន្ថយនូវឧបទ្ទហេតុការជួញដូរស្ត្រីនិងកុមារ និងពង្រឹងការការពារ ការស្តារឡើងវិញ និងសមាហរណកម្មរបស់ពួកគេ។

នគរបាលសហព័ន្ធអូស្ត្រាលី និងទីភ្នាក់ងារដើម្បីការអភិវឌ្ឍន៍អន្តរជាតិ កំពុងធ្វើសហប្រតិបត្តិការយ៉ាងសកម្មជាមួយក្រសួងនានា ដូចជា ក្រសួងមហាផ្ទៃ យុត្តិធម៌ និងកិច្ចការនារីជាដើម ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនេះ។

ចំពោះព័ត៌មានបន្ថែម សូមរកមើលក្នុងវេបសាយ http://www.ausaid.gov.au/country/peopletraffick.cfm.


**ទំនាក់ទំនងការផ្សាយៈ លោកស្រី ហ្វីយុណា ខស្ស លេខាទី១**

**ទូរស័ព្ទលេខៈ ០២៣ ២១៣ ៤៧០ ស្ថានទូតអូស្ត្រាលីនៅភ្នំពេញ**


**ថ្ងៃទី៦ ខែមិនា ឆ្នាំ២០០៩**